# សេចក្តីប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិ
# នៅតំបន់ហតស្ពត ឥណ្ឌូ-ភូមា

**កាលបរិច្ឆេទចាប់ផ្តើមទទួល៖** ០៨ មករា ឆ្នាំ២០២១

**កាលបរិច្ឆេទឈប់ទទួល៖** ០៥ កុម្ភៈ ឆ្នាំ២០២១

**ទំហំមូលនិធិ៖** ខ្នាតតូច (ត្រឹម៥០.០០០ដុល្លារសហរដ្ឋអាមេរិក) និងខ្នាតធំ(ចាប់ពី៥០.០០០ដុល្លារសហរដ្ឋអាមេរិក ដល់២៥០.០០០ដុល្លារសហរដ្ឋអាមេរិក)

**ប្រទេសដែលមានសិទ្ធិដាក់៖** កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃឡង់ដ៍ និងវៀតណាម

**អាទិភាព៖** ផ្តោតលើទិសដៅយុទ្ធសាស្ត្រទី១ និង២ និងអាទិភាពនៃការវិនិយោគ ៨.៣

**ភាសា:** លេខាធិការដ្ឋានមូលនិធិ CEPF ទទួលសំណើគម្រោងសុំមូលនិធិខ្នាតធំជាភាសាអង់គ្លេស បារាំង ព័រទុយហ្គាល់ និងអេស្ប៉ាញ។ អង្គការ IUCN ទទួលសំណើគម្រោងសុំមូលនិធិខ្នាតតូចជាភាសាខ្មែរ ចិន អង់គ្លេស ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង (CEPF) និងអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) សូមប្រកាសចាប់ផ្តើមទទួលយកសំណើគម្រោងសុំមូលនិធិពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ អង្គការរបស់ជនជាតិដើមភាគតិច ក្រុមស្ត្រី ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត សម្រាប់គម្រោងទាំងឡាយណា ដែលដោះស្រាយនូវបញ្ហានៃការអភិរក្សជីវចម្រុះនៅតំបន់ហតស្ពតឥណ្ឌូ-ភូមា និងដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងសេចក្តីប្រកាសនេះ។

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង (CEPF) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារតំបន់ដែលរងការគម្រាមកំហែង និងសំបូរទៅដោយធនធានជីវចម្រុះច្រើនបំផុតនៅលើភពផែនដី ដែលស្គាល់ថាជាតំបន់ហតស្ពតជីវចម្រុះ (Biodiversity hotspots)។ មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែងនេះ គឺជាកិច្ចផ្តួចផ្តើមរួមមួយរវាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង អង្គការអភិរក្សអន្តរជាតិ សហភាពអឺរ៉ុប មូលនិធិបរិស្ថានពិភពលោក រដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក។ នៅតំបន់ហតស្ពតជីវចម្រុះឥណ្ឌូ-ភូមា មូលនិធិ CEPF ក៏ត្រូវបានគាំទ្រដោយមូលនិធិម៉ាហ្គារ៉ែតអា.កាហ្គើលផងដែរ។ គោលបំណងសំខាន់មួយគឺដើម្បីធានាឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងការអភិរក្សជីវចម្រុះ។

តំបន់ហាតស្ពតឥណ្ឌូ-ភូមា រួមមាន តំបន់ទាំងអស់ ដោយមិនរាប់បញ្ចូលនូវតំបន់សមុទ្រនៃប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ាថៃនិងវៀតណាម រួមទាំងផ្នែកខ្លះនៃភាគខាងត្បូងប្រទេសចិន។

ការប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិលើកនេះ គឺទទួលយកតែសំណើគម្រោងទាំងឡាយណា ដែលដោះស្រាយអាទិភាពនៃការវិនិយោគមួយឬពីរ ដូចខាងក្រោមនេះ។ មូលនិធិ CEPF រំពឹងថានឹងចេញប្រកាសថ្មីទៀត ដែលផ្តោតលើអាទិភាពនៃការវិនិយោគផ្សេងទៀត ក្នុងឆ្នាំ២០២១ និង២០២២។ សេចក្តីប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិទាំងនេះ នឹងធ្វើឡើងនៅលើវ៉េបសាយCEPF និងព្រឹត្តិបត្រព័ត៌មានតាមអ៊ីនធឺណែត។

មូលនិធិនឹងផ្តល់ជូនចំពោះគម្រោង ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ៖ (i) មានលក្ខណៈសង្គតិភាពល្អបំផុតទៅនឹងអាទិភាពវិនិយោគ ដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសនេះ។(ii) មានលទ្ធភាពខ្ពស់ក្នុងការសម្រេចបាននូវទិសដៅដែលបានកំណត់ និងរួមចំណែកជាសារវន្តដល់លទ្ធផលអភិរក្សប្រកបដោយនិរន្តរភាព។ (iii) បំពេញបន្ថែមលើគំនិតផ្តួចផ្តើមកន្លងមកនិងគំនិតផ្តួចផ្តើមដែលមានជាបន្តបន្ទាប់; (iv) ជាគម្រោងដែលមានគុណតម្លៃខ្ពស់ និង(v) បង្ហាញពីសមត្ថភាពស្ថាប័ន និងបទពិសោធន៍ចាំបាច់ ក្នុងការអនុវត្តគម្រោងនេះ។ មូលនិធិ CEPF សូមស្វាគមន៍ចំពោះសំណើគម្រោងសុំមូលនិធិពីបណ្តាអង្គការដៃគូទទួលមូលនិធិ បច្ចុប្បន្ននិងអតីតកាល ក៏ដូចជាអង្គការដែលមិនធ្លាប់ទទួលបានមូលនិធិពី CEPF ពីមុន។

អ្នកដាក់សំណើគម្រោងសុំមូលនិធិទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យមានការឈ្វេងយល់បន្ថែមតាមរយៈ Ecosystem Profile សម្រាប់តំបន់ឥណ្ឌូ-ភូមា និងទាក់ទងក្រុមការងារគ្រប់គ្រងមូលនិធិ CEPF ប្រចាំនៅតំបន់ហាតស្ពតឥណ្ឌូ-ភូមា នៃអង្គការ IUCN តាមរយៈ(អ៊ីម៉ែល: CEPF-Indoburma@iucn.org) ប្រសិនបើអ្នកមានសំណួរឬ ចង់ពិភាក្សាអំពីគំនិតនានាដែលអ្នកចង់លើកឡើងក្នុងគម្រោងរបស់អ្នក។ អ្នកដាក់សំណើគម្រោងសុំមូលនិធិ ត្រូវបានលើកទឹកចិត្តឲ្យចូលមើលបន្ថែមលើគេហទំព័រ CEPF ជាពិសេសផ្នែកស្តីពី លក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំមូលនិធិមុនពេលអ្នកដាក់ពាក្យ និងរបៀបដាក់ពាក្យ។

## <u>អាទិភាពដែលនឹងផ្តល់មូលនិធិក្នុងសេចក្តីប្រកាសលើកនេះ</u>

### ទិសដៅយុទ្ធសាស្ត្រទី១៖ ការពារប្រភេទដែលរងការគម្រាមកំហែងជាសកលជាអាទិភាព ដោយកាត់បន្ថយការគម្រាមកំហែងចំបង

*សម្គាល់:* គម្រោងដែលបានលើកឡើង ត្រូវតែផ្តោតលើប្រភេទអាទិភាពមួយឬច្រើន ដែលបង្ហាញក្នុងតារាងទី២៨ នៅក្នុងឯកសារស្ថានភាពប្រព័ន្ធអេកូឡូស៊ី ឬប្រភេទកង្កែប Ailao (Bufo ailaoanus) ដែលបានក្លាយជាប្រភេទអាទិភាពសំរាប់ការវិនិយោគរបស់មូលនិធិ CEPF បន្ទាប់ពីការវាយតំលៃឡើងវិញពីស្ថានភាពគម្រាមកំហែងជាសកលរបស់ខ្លួនក្នុងបញ្ជីក្រហមអង្គការ IUCN។

លេខាធិការដ្ឋានមូលនិធិ CEPF និងអង្គការ IUCN សូមប្រកាសទទួលយកសំណើគម្រោងដែលដោះស្រាយអាទិភាពនៃការវិនិយោគមួយឬច្រើនជាងមួយ ដូចខាងក្រោម៖

១.១ ទ្រទ្រង់កម្មវិធីអភិរក្សរយៈពេលវែងសម្រាប់ប្រភេទសួលនៃប្រភេទជាអាទិភាព

១.២ស្តារនូវចំនួននៃប្រភេទសត្វព្រៃជាអាទិភាពដែលអាចរស់នៅបានស្របតាមគោលការណ៍ណែនាំសកល

១.៣ ស្រាវជ្រាវប្រភេទសត្វដែលរងការគម្រាមកំហែងជាសកល ដើម្បីបង្កើតឲ្យមានទិន្នន័យ ឬព័ត៌មានស្តីពីស្ថានភាព និងរបាយរស់នៅ

១.៤ ស្រាវជ្រាវ និងសាកល្បងប្រភពមូលនិធិ ដែលមានលក្ខណៈនវានុវត្តន៍ សម្រាប់ការអភិរក្សប្រភេទ

១.៥ គាំទ្រដល់បុគ្គលឆ្នើមខាងការពារសត្វព្រៃនៅកម្រិតថ្នាក់សហគមន៍ ដើម្បីអនុវត្តសកម្មភាពមូលដ្ឋានសម្រាប់ប្រភេទសត្វអាទិភាព

**ទិសដៅយុទ្ធសាស្ត្រទី២៖ កាត់បន្ថយហានីភ័យនៃការកើតឡើងនូវជម្ងឺសត្វព្រៃ ដោយកាត់បន្ថយការជួញដូរខុសច្បាប់ បរិភោគសាច់សត្វព្រៃ និង ការគម្រាមកំហែងលើសត្វព្រៃ**

លេខាធិការដ្ឋានមូលនិធិ CEPF និងអង្គការ IUCN សូមប្រកាសទទួលយកសំណើគម្រោងដែលដោះស្រាយអាទិភាពនៃការវិនិយោគមួយឬច្រើនជាងមួយ ដូចខាងក្រោម៖

២.១ គាំទ្រភ្នាក់ងារអនុវត្តច្បាប់ ដើម្បីលាតត្រដាញការជួញដូរសត្វព្រៃ ដែលមានលក្ខណៈជាបណ្តាញកម្រិតខ្ពស់ ដោយលើកកម្ពស់ការអនុវត្តល្អបំផុតជាសកលជាមួយការស៊ើបអង្កេត ការស៊ើបការណ៍ចារកម្ម និងអ្នករាយការណ៍

២.២ សម្របសម្រួលកិច្ចសហការក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ ដែលចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃខុសច្បាប់ ព្រមទាំងវិស័យដទៃទៀតដែលជាផ្នែកនៃវិធីសាស្ត្រសុខភាពតែមួយ

២.៣ ធ្វើការជាមួយក្រុមហ៊ុនឯកជន និងរដ្ឋ ដែលផ្តោតជាពិសេសលើផ្នែកភស្តុភារ និងវេទិកាអនឡាញ ដើម្បីកាត់បន្ថយការពាក់ព័ន្ធរបស់ពួកគេក្នុងការជួញដូរសត្វព្រៃ

២.៤ គាំទ្រដល់យុទ្ធនាការតាមគោលដៅ ដើម្បីកាត់បន្ថយតម្រូវការ និងប្រមូលការចូលរួមជាសាធារណៈក្នុងការតាមដានស្វែងរក និងរាយការណ៍អំពីឧក្រិដ្ឋកម្មសត្វព្រៃ

២.៥ យល់ដឹង និងគាំទ្រសកម្មភាពដែលពាក់ព័ន្ធនឹងការផ្សារភ្ជាប់គ្នារវាងជីវចម្រុះនិងសុខភាពមនុស្ស រួមទាំងតួនាទីនៃការបាត់បង់ជីវចម្រុះដែលនាំឲ្យមានការកើតមានឡើងនូវជម្ងឺសត្វព្រៃ

**ទិសដៅយុទ្ធសាស្ត្រទី៨៖ ពង្រឹងសមត្ថភាពសង្គមស៊ីវិល ដើម្បីធ្វើការលើជីវៈចម្រុះ សហគមន៍ និងជីវភាពរស់នៅនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន**

លេខាធិការដ្ឋានមូលនិធិ CEPF និងអង្គការ IUCN សូមប្រកាសទទួលយកសំណើគម្រោងដែលដោះស្រាយអាទិភាពនៃការវិនិយោគ ដូចខាងក្រោម៖

៨.៣ បង្កើតឲ្យមានយន្តការផ្សារភ្ជាប់អ្នកស្ម័គ្រចិត្តទៅនឹងការបំពេញតម្រូវការបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិល

## ព័ត៌មានបន្ថែម

សេចក្តីប្រកាសនេះ គឺបើកចំហចំពោះបណ្តាអង្គជាតិ និងអន្តរជាតិ ក្នុងតំបន់ហាតស្ពតឥណ្ឌូ-ភូមា។ រាល់បុគ្គល ដែលមានបំណងដាក់សំណើសុំមូលនិធិ ត្រូវធ្វើការជាមួយអង្គការសង្គមស៊ីវិល ដើម្បីសរសេរសំណើគម្រោងសុំមូលនិធិនេះ ជាជាងការដាក់ស្នើសុំជាលក្ខណៈបុគ្គល។ សូមកត់សម្គាល់ថា មូលនិធិនឹងត្រូវផ្តល់ទៅឲ្យគម្រោងដែលបង្ហាញពីតួនាទីឈានមុខគេសម្រាប់អង្គការក្នុងស្រុកនានានិង/ឬការផ្តោតសង្កត់ធ្ងន់ជាក់លាក់លើការកសាងសមត្ថភាពសម្រាប់សង្គមស៊ីវិលមូលដ្ឋាន។ ក៏នឹងមានការផ្តល់ជូនផងដែរ ដល់គម្រោងទាំងឡាយណាដែល បានគិតគូរពីបញ្ហាយេនឌ័រស្របតាមគោលនយោបាយយេនឌ័រនិងឧបករណ៍ណែនាំស្តីពីយេនឌ័រនៃមូលនិធិ CEPF។

មូលនិធិដែលផ្តល់ឲ្យមិនអាចយកទៅប្រើប្រាស់សម្រាប់៖ (១) ទិញដី (២) សកម្មភាពរុះរើ ឬធ្វើឲ្យខូចដល់ទ្រព្យសម្បត្តិវប្បធម៌រូបវន្ត (ដូចជា ទីតាំងដែលមានតម្លៃផ្នែកបុរាណវត្ថុវិទ្យា ផ្នែកបាសាណិភូតវិទ្យា ផ្នែកប្រវត្តិសាស្ត្រ សាសនា ឬក៏តម្លៃរបស់ធម្មជាតិដែលមានតែមួយ (៣) ផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ឬក៏ការ រុះរើតាំងទីលំនៅសារជាថ្មីដោយគ្មានការស្ម័គ្រចិត្ត (៤) យកទៅផ្គត់ផ្គង់បន្ថែមទៅលើមូលនិធិអាណាព្យាបាលភាព (ត្រាស់ហ្វាន់)។ រាល់សកម្មភាព ទាំងអស់ត្រូវគោរពតាមគោលនយោបាយការពារសុវត្ថិភាពសង្គមនិងបរិស្ថានរបស់មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង ដែលអាចរកបាន សូមចុចត្រង់នេះ។

## របៀបដាក់សំណើគម្រោង

**អ្នកលើកសំណើគម្រោងសុំមូលនិធិខ្នាតតូច (ត្រឹម ៥០.០០០ដុល្លារសហរដ្ឋអាមេរិក)** អាចដាក់ជាភាសាខ្មែរ អង់គ្លេស ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដោយប្រើគំរូសំណើគម្រោង ដែលមាន សូមចុចត្រង់នេះ។ គម្រោងដែលបានលើកឡើងគួរមានរយៈពេលពី ០១ ទៅ ០២ ឆ្នាំ ជាមួយនឹងការគ្រោងចាប់ផ្តើមអនុវត្តគម្រោងចាប់ពីថ្ងៃទី ០១ កក្កដា ឆ្នាំ២០២១ទៅ។ នៅពេលសំណើត្រូវបានរៀបចំរួច សូមផ្ញើអ៊ីម៉ែលមកកាន់ CEPF-Indoburma@iucn.org។

សូមដាក់ឈ្មោះសំណើសុំមូលនិធិរបស់ស្ថាប័នរបស់អ្នកក្នុងទម្រង់ដូចនេះ៖ **អក្សរកាត់អង្គការរបស់អ្នក_CEPF SG Call 1**។ ជាឧទាហរណ៍៖ IUCN_CEPF SG Call 1។ ការទទួលបាននូវសំណើគម្រោងរបស់

អ្នកនឹងត្រូវជម្រាបជូនតាមរយៈអ៊ីម៉ែល។ លោក លោកស្រីនឹងត្រូវបានទាក់ទងពីជំហាន ដែលនឹងត្រូវធ្វើបន្ទាប់ទៀត ប្រសិនបើសំណើរបស់លោក លោកស្រី ជាប់នៅដំណាក់កាលទី១។ រាល់សំណួរ ឬចម្ងល់ក្នុងអំឡុងពេលនៃដំណើរការលើកសំណើសុំនេះ អាចសាកសួរបានតាមរយៈអ៊ីម៉ែល៖CEPF-Indoburma@iucn.org ។

រាល់សំណើគម្រោងទាំងអស់នឹងត្រូវពិនិត្យវាយតម្លៃដើម្បីបញ្ជាក់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ រាល់សំណើគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយ នឹងត្រូវពិនិត្យមើលឡើងវិញជាបឋម តាមលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើ។ បន្ទាប់មក សំណើគម្រោងដែលបានជាប់សំរាំងនឹងយកទៅពិនិត្យមើល និងវាយតម្លៃថែមទៀតនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិ។ ការសម្រេចនឹងផ្តល់មូលនិធិដល់សំណើគម្រោងណានោះ គឺមានការពិចារណាទៅលើអនុសាសន៍ពីកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ថ្នាក់ជាតិនេះ។

អ្នកដាក់សំណើគម្រោងសុំមូលនិធិខ្នាតធំ (លើសពី៥០.០០០ ដល់ ២៥០.០០០ដុល្លារសហរដ្ឋអាមេរិក) ត្រូវតែដាក់តាមរយៈកម្មវិធីតាមអ៊ីនធើណែត ConservationGrants។ លោកអ្នកដែលដាក់សំណើគម្រោង លើកទី១ចាំបាច់ត្រូវចុះឈ្មោះដំបូងសិនដើម្បីបង្កើតគណនេយ្យ។ រាល់អ្នកដាក់សំណើណា ដែលជួបប្រទះបញ្ហាបច្ចេកទេសជាមួយនឹងកម្មវិធីផតថលតាមអនឡាញ គួរតែទាក់ទងមក៖ conservationgrants@conservation.org។

ជំហានដំបូងនៃដំណើរការដាក់ពាក្យសុំមូលនិធិ គឺត្រូវដាក់ឯកសារគោលគំនិតខ្លីនៃគម្រោងតាមរយៈអនឡាញជាមុនសិន។ ឯកសារគោលគំនិតខ្លីនៃគម្រោង អាចដាក់បាន ជាភាសាអង់គ្លេស បារាំង ព័រទុយហ្កាល់ ឬអេស្ប៉ាញ។ អ្នកស្នើសុំត្រូវបានណែនាំឱ្យរៀបចំឯកសារគោលគំនិតខ្លីនៃគម្រោងដែលមានរយៈពេលចាប់ពី ០១-០៣ ឆ្នាំជាមួយនឹងកាលបរិច្ឆេទចាប់ផ្តើមប៉ាន់ស្មានថ្ងៃទី ០១ ខែកក្កដាឆ្នាំ ២០២១។ ឯកសារគោលគំនិតខ្លីនៃគម្រោង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវឆ្លងកាត់ការពិនិត្យបច្ចេកទេសដោយលេខាធិការដ្ឋាន CEPF និងអង្គការ IUCN ដោយប្រើលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ខាងលើ។ អ្នកដាក់សំណើគម្រោងសុំមូលនិធិ ដែលជាប់ក្នុងបញ្ជីសម្រាំង នឹងត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញពីគម្រោងរបស់ពួកគេទៅកាន់គណៈកម្មាធិការត្រួតពិនិត្យនិងវាតតម្លៃ ហើយពួកគេនឹងត្រូវបានជូនដំណឹងជាបន្ត បន្ទាប់ថាតើពួកគេត្រូវបានអញ្ជើញមកកាន់ដំណាក់កាលសំណើគម្រោងពេញលេញឬអត់។

អ្នកដាក់សំណើគម្រោងសុំមូលនិធិ ដែលបានជាប់នៅដំណាក់កាលទី១ គោលគំនិតខ្លីនៃគម្រោងនឹងត្រូវបានអញ្ជើញតាមរយៈលិខិតផ្លូវការឲ្យដាក់សំណើគម្រោងពេញលេញ ជាមួយនឹងការផ្តល់នូវការណែនាំលំអិតស្តីពីការរៀបចំសំណើគម្រោងពេញលេញ ដោយនឹងផ្តល់រយៈពេល ៦សប្តាហ៍ក្នុងការរៀបចំសំណើគម្រោងពេញលេញតាមរយៈកម្មវិធីវិបសាយ (ផតថល)។ ក្នុងអំឡុងពេលនោះ អ្នកដាក់សំណើគម្រោងដែលបានជាប់នៅដំណាក់កាលទី១ នឹងត្រូវបានអញ្ជើញឲ្យចូលរួម សិក្ខាសាលាស្តីពីការសរសេរសំណើគម្រោង ដែលជាឱកាសពង្រឹងដល់ការរៀបចំសំណើរគម្រោងរបស់ពួកគេ ដោយមានការសហការគ្នាជាក្រុម ដោយមានការណែនាំពីលេខាធិការដ្ឋាន CEPF និងបុគ្គលិកអង្គការIUCN។

**រាល់អ្នកដាក់សំណើគម្រោងទាំងអស់ ត្រូវដាក់សំណើរបស់ខ្លួនឲ្យបានត្រឹមម៉ោង ៥ ល្ងាច (ម៉ោងនៅតំបន់ឥណ្ឌូចិន) នាថ្ងៃទី០៥ កុម្ភៈ ឆ្នាំ២០២១។** រាល់សំណើទាំងឡាយណាដែលទទួលបានក្រោយវេលាម៉ោងនេះនឹងត្រូវបដិសេធ។ អ្នកដាក់សំណើគម្រោង នឹងទទួលបានអ៊ីម៉ែល ដោយបញ្ជាក់នូវការទទួលបានការដាក់សំណើគម្រោងរបស់អ្នក។

លោកអ្នកអាចពិនិត្យចម្លើយចំពោះសំណួរដែលតែងតែសួរជារឿយៗ ត្រង់នេះ

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**


ក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់នៃមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង

ការិយាល័យអង្គការ IUCN ប្រចាំតំបន់អាស៊ី

#៦៣ តំបន់សុខុមវីត ៣៩ វឌ្ឍថានា បាងកក ១០១១០ ថៃឡង់ដ៍

អ៊ីម៉ែលៈ CEPF-Indoburma@iucn.org

ទូរស័ព្ទៈ +៦៦ ២ ៦៦២ ៤០២៩ ទូរសារៈ +៦៦ ២ ៦៦២ ៤៣៨៩